# របាយការណ៍
# ស្ដីពី
# "វឌ្ឍនភាព និងទិសដៅការងារបន្ត របស់ក្រុមប្រឹក្សាខេត្តកំពង់ចាម"
# ក្នុងសន្និសីទសារព័ត៌មាននៅទីស្ដីការគណៈរដ្ឋមន្ត្រី

## ឯកឧត្តម ខ្លូត ផន ប្រធានក្រុមប្រឹក្សាខេត្តកំពង់ចាម

(ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២)

-សូមក្រាបថ្វាយបង្គំ សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ **ជាទីគោរពសក្ការៈ**

-សូមក្រាបបង្គំទូលថ្វាយព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះមហាក្សត្រី **មុនីនាថ សីហនុ** ព្រះវររាជមាតា **ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**

-សូមគោរពសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

-សូមគោរព សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **ជាទីគោរពដ៏ខ្ពង់ខ្ពស់**

-សូមគោរព **ឯកឧត្តម ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ***ជាទីគោរពដ៏ខ្ពង់ខ្ពស់ !***

-ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសន្និសីទសារព័ត៌មាននាពេលនេះ ***ជាទីមេត្រី !***

-បងប្អូនប្រជាពលរដ្ឋដែលកំពុងទស្សនាការផ្សាយផ្ទាល់ ***ជាទីគោរពស្រលាញ់រាប់អាន!***

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានរៀបចំសន្និសីទសារព័ត៌មាន ស្ដីពី "**វឌ្ឍនភាពមូលដ្ឋាន ឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់ខេត្តកំពង់ចាម**" និងសូមអរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលបានចូលរួមក្នុងសន្និសីទនាឱកាសនេះ។

ក្នុងនាមក្រុមប្រឹក្សា គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋក្នុងខេត្តកំពង់ចាមទាំងមូល ខ្ញុំសូមយកឱកាសនេះសម្ដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលជាបិតាស្ថាបនិកសន្តិភាពជូនប្រទេស និងពលរដ្ឋកម្ពុជា "**សូមអរគុណសន្តិភាព**" ដែលធ្វើឲ្យប្រទេសជាតិមានសុខសន្តិភាព ស្ថិរភាព នយោបាយ សុវត្ថិភាពសង្គម និងមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ។

ខ្ញុំបាទសូមការអនុញ្ញាតិជម្រាបជូនអង្គសន្និសីទសារព័ត៌មាន អំពីលក្ខណៈភូមិសាស្ត្រ ប្រជាសាស្ត្រ ស្ថានភាព និងវឌ្ឍនភាពការងាររបស់ក្រុមប្រឹក្សាខេត្តកំពង់ចាម និងទិសដៅអនុវត្តការងារបន្ត ដែលមានដូចតទៅ៖

## I.អំពីលក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្រ ៖

ខេត្តកំពង់ចាមស្ថិតនៅតាមបណ្តាយដងទន្លេមេគង្គ ដែលមានចម្ងាយ ១២៤គ.ម ពីរាជធានីភ្នំពេញ ដោយឆ្លងកាត់តាមផ្លូវជាតិលេខ៦ និងផ្លូវជាតិលេខ៧ មានព្រំប្រទល់៖

- ខាងកើតទល់នឹងខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ
- ខាងលិចទល់នឹងខេត្តកំពង់ឆ្នាំង
- ខាងជើងទល់នឹងខេត្តកំពង់ធំ
- ខាងត្បូងទល់នឹងខេត្តព្រៃវែង និងខេត្តកណ្តាល
- មានក្រុង ០១ ស្រុក ០៩ សង្កាត់ ០៤ និង ១០៥ឃុំ ស្មើនឹង ៩១៦ភូមិ
- ផ្ទៃដីសរុបមានចំនួន៖ ៤.៥៤៨,០៩គីឡូម៉ែត្រការ៉េ
- ស្ថានភាពដី ចែកជាបីប្រភេទ ៖ តំបន់ដងទន្លេ ,វាលទំនាប និងខ្ពង់រាប
- មានប្រជាពលរដ្ឋរស់នៅចំនួន ៖ ២៨៣.២៥៩គ្រួសារ
- មនុស្សសរុបចំនួន ៖ ១.១០៥.១៤៨នាក់ ស្រី ៥៧០.៥៤៥នាក់
- ប្រជាជនមានអាយុ១៨ឆ្នាំឡើង មានចំនួន ៖ ៧៥៥១៨១.នាក់ ស្រី ៣៩៦៣០៤.នាក់
- ដង់ស៊ីតេប្រជាពលរដ្ឋ ៖ ២៤៥នាក់/គ.ម$^{២}$

❖ សក្តានុពលខេត្តកំពង់ចាម ពឹងផ្អែកលើវិស័យកសិកម្មជាចម្បងចំនួន ៦៤,២០%

- ឧស្សាហកម្ម និងសិប្បកម្ម ០,៦៧% និងរបរសេវាកម្ម ៣៥,១៣%
- GDP របស់មនុស្សម្នាក់ៗទទួលបាន ១.៦៧៩ដុល្លារអាមេរិក
- អត្រាភាពក្រីក្រថយចុះមកត្រឹម ១៣,២% នៅឆ្នាំ២០២១ តាមរយៈទិន្នន័យភូមិ ឃុំ

## II-អំពីស្ថានភាព និងវឌ្ឍនភាពការងាររបស់ក្រុមប្រឹក្សាខេត្តកំពង់ចាម

បន្ទាប់ពីប្រទេសកម្ពុជាយើងទទួលបាននូវសុខសន្តិភាព ពេញលេញនៅចុងឆ្នាំ១៩៩៨ តាមរយៈនយោបាយឈ្នះៗ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការ ក្នុងគោលបំណងបង្វិតសេវាសាធារណៈឲ្យកាន់តែនៅកៀកនឹងប្រជាពលរដ្ឋ ព្រមទាំងបានធ្វើការកែលម្អការផ្តល់សេវានានា និងជំរុញការអភិវឌ្ឍនៅមូលដ្ឋាន ប្រកបដោយតម្លាភាព រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ផ្អែកលើក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាល បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័ត

នៅខែឧសភា ឆ្នាំ២០០៨ ។ តាមរយៈនៃច្បាប់នេះ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតឡើងតាមការបោះឆ្នោតអសកលឆ្នាំ២០០៩ កន្លងមក។

អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន ក្រុមប្រឹក្សាបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ តាមរយៈការដាក់ចេញដីកា និងសេចក្តីសម្រេចនានាក្នុងអង្គប្រជុំក្រុមប្រឹក្សា និងធានាថាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ ។

❖ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា។

❖ រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីសម្រេច ឬដីកាតាមការចាំបាច់ទាក់ទិនទៅនឹង ៖

-មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា

-មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

-កម្មវិធីវិនិយោគបីឆ្នាំរំកិល ប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ រួមទាំងសមាសភាគនៃផែនការនោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួត ពិនិត្យរបស់ក្រុមប្រឹក្សា រួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា។

-គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

-ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា។

-ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ។

❖ គណៈអភិបាល ត្រូវផ្តល់យោបល់ជូនក្រុមប្រឹក្សា រាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។

❖ គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សា ដើម្បីឲ្យក្រុមប្រឹក្សាសម្រេចបាននូវការអនុវត្តមុខងារ សិទ្ធិអំណាច និងភារកិច្ចរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃច្បាប់។

❖ គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សាក្នុងការពិនិត្យមើលមុខងារ ភារកិច្ច និងធនធានទាំងអស់ ដែលបានបែងចែក ឬបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយច្បាប់ ឬដែលស្របតាមច្បាប់ រួចហើយត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាអំពីរបៀបបំពេញមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ ។

សម្រាប់អាណត្តិទី៣នេះ ក្រុមប្រឹក្សាខេត្តកំពង់ចាម មានសមាជិកចំនួន ២៧រូប ស្រី ០៤រូប ក្រុមប្រឹក្សាក្រុង ស្រុក ទាំង១០ ក្នុងខេត្តកំពង់ចាម មាន២០៤រូប ក្រុមប្រឹក្សាឃុំ សង្កាត់ មាន ៨១៧រូប ។

❖ **ក្រុមប្រឹក្សាខេត្តកំពង់ចាម មានគណៈកម្មាធិការកាតព្វកិច្ចចំនួន ០៣ ៖**

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដែលមានឯកឧត្តមអភិបាលខេត្តជាប្រធាន អភិបាលរងខេត្តមួយរូប ជាអនុប្រធាន សមាជិកក្រុមប្រឹក្សាខេត្ត ០៥រូប ជាសមាជិក និងមានប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត នាយករដ្ឋបាល នាយកទីចាត់ការ និងប្រធានអង្គភាព ចំណុះសាលាខេត្ត អភិបាល ក្រុង ស្រុក ជាសមាជិក។ គណៈកម្មាធិការនេះ មានមុខងារ ភារកិច្ចសម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ជាមួយមន្ទីរ អង្គភាព ការិយាល័យរបស់ក្រសួង ស្ថាប័ននានា និងរៀបចំតាក់តែងសេចក្តីព្រាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម របស់រដ្ឋបាលខេត្ត ។ រយៈពេលឆ្នាំ២០២១នេះ បានបើកកិច្ចប្រជុំ ចំនួន ០៥លើក។

- គណៈកម្មាធិការលទ្ធកម្ម ដែលមានឯកឧត្តម អភិបាលខេត្ត ជាប្រធាន អភិបាលរងខេត្ត០១រូប ជាអនុប្រធាន សមាជិកក្រុមប្រឹក្សាខេត្ត ចំនួន ០៣រូប ជាសមាជិក នាយករដ្ឋបាល ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាយកទីចាត់ការហិរញ្ញវត្ថុ និងប្រធានអង្គភាពលទ្ធកម្ម ជាសមាជិក។ គណៈកម្មាធិការលទ្ធកម្មនេះ មានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលរៀបចំដោយអង្គភាពលទ្ធកម្ម ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងឯកភាព មុននឹងផ្ញើជូនក្រសួងសេដកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងអនុម័ត។ ក្នុងឆ្នាំ២០២១នេះ បានបើកកិច្ចប្រជុំចំនួន ៤៥លើក។

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ដែលមានសមាជិកក្រុមប្រឹក្សា ០១រូបជាស្ត្រី ជាប្រធាន សមាជិកាក្រុមប្រឹក្សាខេត្ត ០១រូបទៀត ជាអនុប្រធាន អភិបាលរងខេត្តជាស្ត្រី ០១រូប ជាអនុប្រធាន និងប្រធានមន្ទីរ ឬអនុប្រធានមន្ទីរ អង្គភាព មួយចំនួន ជាស្ត្រី ជាសមាជិក។ គណៈកម្មាធិការនេះ មានភារកិច្ច រៀបចំ និងផ្តល់យោបល់ និងលើកអនុសាសន៍ជូនក្រុមប្រឹក្សា គណៈអភិបាល និងគណៈកម្មាធិការដទៃទៀត របស់ក្រុមប្រឹក្សា ពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី និងកុមារ ហើយក្នុងរយៈពេលឆ្នាំ២០២១ បានបើកកិច្ចប្រជុំចំនួន ១៤លើក និងចុះធ្វើសកម្មភាពទៅតាមមូលដ្ឋាន ក្រុង ស្រុក ឃុំ សង្កាត់ ចំនួន ១៧លើក។

ដោយអនុវត្តតាមតួនាទី និងភារកិច្ច ដែលបានកំណត់ នៅឆ្នាំ២០២១នេះ ក្រុមប្រឹក្សាខេត្តកំពង់ចាម សម្រេចបានការងារសំខាន់ៗរួមមាន៖

➢ **កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញ**

ក្នុងអាណត្តិទី៣ ក្រុមប្រឹក្សាខេត្ត បានដឹកនាំកិច្ចប្រជុំសាមញ្ញរបស់ខ្លួន បានទៀងទាត់ជាប្រចាំខែទៅតាមប្រតិទិន និងបទបញ្ជាផ្ទៃក្នុង របស់ក្រុមប្រឹក្សាខេត្ត ដើម្បីពិនិត្យ ពិភាក្សា និងអនុម័ត

លើសេចក្តីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិ រួមមាន៖ សេចក្តីព្រាងផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ (២០២០-២០២៤) និងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល( ២០២១-២០២៣ ) សេចក្តីព្រាងផែនការថវិកាចំណូល ចំណាយ របាយការណ៍រីកចម្រើនរបស់រដ្ឋបាលខេត្ត និងអនុម័តសេចក្តីព្រាងដីកា សេចក្តីសម្រេច សេចក្តីណែនាំនានា ក្នុងសមត្ថកិច្ចរបស់ខ្លួន។ ក្នុងឆ្នាំ២០២១ក្រុមប្រឹក្សាខេត្តបានធ្វើការប្រជុំសាមញ្ញចំនួន ១២លើក។

ក្រៅពីកិច្ចប្រជុំសាមញ្ញក្រុមប្រឹក្សាខេត្តកំពង់ចាម ក៏បានរៀបចំកិច្ចប្រជុំវិសាមញ្ញដើម្បីដោះស្រាយបញ្ហាជាបន្ទាន់ ឬពិសេសតាមសំណើរបស់ឯកឧត្តមអភិបាលខេត្ត ដែលក្នុងឆ្នាំ២០២១ បានប្រជុំជាវិសាមញ្ញចំនួន ០៤លើក។

❖ បញ្ហាគួរឲ្យកត់សម្គាល់ ក្រុមប្រឹក្សាខេត្តបានរៀបចំកិច្ចប្រជុំរបស់ខ្លួន ដោយមានការអញ្ជើញ ចូលរួមពីឯកឧត្តមអភិបាល អភិបាលរងខេត្ត ប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត នាយករដ្ឋបាល នាយកទីចាត់ការ និងប្រធានអង្គភាពនានាចំណុះសាលាខេត្ត ស្នងការនគរបាលខេត្ត មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ព្រមទាំងធ្វើការពិភាក្សាក្នុងអង្គប្រជុំបានផុសផុល លើកឡើងជាសំណួរ និងសំណូមពរ ព្រមទាំងធ្វើការឆ្លើយបំភ្លឺពីបណ្តាមន្ទីរ អង្គភាពជំនាញ និងអ្នកពាក់ព័ន្ធប្រកបដោយការទទួលខុសត្រូវ ។ ក្រុមប្រឹក្សាខេត្តកំពង់ចាម បានធ្វើការបែងចែកសមាជិករបស់ខ្លួន ឲ្យចុះតាមបណ្តាក្រុង ស្រុក មន្ទីរ អង្គភាព ជួបប្រាស្រ័យជាមួយក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់ មន្ត្រីរាជការ និងប្រជាពលរដ្ឋស្វែងយល់អំពី សភាពការណ៍ បញ្ហាប្រឈម និងសំណូមពរចាំបាច់នានា នៅមូលដ្ឋាន ដើម្បីលើកជាយោបល់ជូនអង្គប្រជុំរបស់ក្រុមប្រឹក្សាធ្វើការពិភាក្សា ដោះស្រាយ និងឆ្លើយតប។

➢ **ការងារការិយាល័យប្រជាពលរដ្ឋ**

ផ្អែកតាមអនុក្រឹត្យលេខ១៩អនក្រ បក ចុះថ្ងៃទី០៨ ខែកម្ភៈ ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងសេចក្តីណែនាំលេខ០០៧ សណន ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីរបៀបបធ្វើការងាររបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។ ជាក់ស្តែង ការិយាល័យប្រជាពលរដ្ឋ បានចុះផ្សព្វផ្សាយ និងចែកខិត្តប័ណ្ណពីតួនាទី ភារកិច្ចតាមបែបចល័តនៅទីប្រជុំជន ទីផ្សារ តាមឃុំ សង្កាត់ ក្នុងក្រុង ស្រុក។

ក្នុងបរិបទនៃការទទួល និងសម្របសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការដែលពាក់ព័ន្ធ នឹងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាល នៅឆ្នាំ២០២១នេះ ការិយាល័យប្រជាពលរដ្ឋខេត្ត បានទទួលពាក្យបណ្តឹងសរុបចំនួន ១៦៩ករណី ក្នុងនោះ ក្នុងសមត្ថកិច្ចចំនួន ១១៨ករណី ក្រៅសមត្ថកិច្ច ៣៣ករណី និងព័ត៌មានផ្សេងៗ ១៨ករណី។ បានចុះធ្វើការស្រាវជ្រាវស៊ើបអង្កេត និងផ្តល់អនុសាសន៍ជូនឯកឧត្តមប្រធានក្រុមប្រឹក្សា និងឯកឧត្តមអភិបាលខេត្ត បានចំនួន ១០០ករណី ដើម្បីពិចារណានិងចាត់វិធានការតាមផ្លូវច្បាប់ នៅសល់ ០១ករណីទៀតកំពុងធ្វើការស្រាវជ្រាវបន្ត និងបានបិទសំណុំរឿង ១៧ករណី។

➢ **ការផ្តល់សេវាសាធារណៈ**

-អង្គភាព និងការិយាល័យច្រកចេញចូលតែមួយ មានគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព តាមរយៈការប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលលើវិស័យនានា នៅនឹងកន្លែងតែមួយធានានូវការបង្កិតសេវាកៀក និងជិតប្រជាពលរដ្ឋ។ ក្នុងនោះ អង្គភាព និង ការិយាល័យច្រកចេញចូលតែមួយ បាននិងកំពុងដំណើរការមានអង្គភាពច្រកចេញចូលតែមួយ សាលាខេត្ត និងការិយាល័យច្រកចេញចូលតែមួយទាំង១០ក្រុង ស្រុក ។

ជាក់ស្តែង អង្គភាពច្រកចេញចូលតែមួយខេត្តកំពង់ចាម បានផ្តល់សេវាជូនប្រជាពលរដ្ឋ សរុប ចំនួន ៣៣.៧០៦សេវា ។ ចំពោះ ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក បានផ្តល់សេវាសរុប ចំនួន ១៦២.៦៧៤សេវា ។

- **ការអនុវត្តគោលនយោបាយគាំពារសង្គម**

- ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម០២ឆ្នាំ បានចុះឈ្មោះអ្នកទទួលផល សរុបចំនួន ៦,៤០១នាក់ ក្នុងនោះ ស្ត្រីមានផ្ទៃពោះ ចំនួន ៤,៧៦៣ នាក់ និងកុមារ ចំនួន ១,៦៣៨នាក់ និងអ្នកទទួលផលបានមកអនុវត្តលក្ខខណ្ឌ នៅតាមមណ្ឌល សុខភាព ចំនួន ២៤,១៦០ករណី និងសម្រាលកូន ២,៧៦៤នាក់ ស្មើនឹងទឹកប្រាក់សរុប ២,៨៣៤,២៤០,០០០ រៀល ។

- ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេល ប្រយុទ្ធនឹងជម្ងឺកូវីដ-១៩ មកដល់ជុំទី៧ លើកទី ៣(ខែធ្នូ) ឆ្នាំ២០២១នេះ អ្នកទទួលផលបានមក ផ្ទៀងផ្ទាត់ និងបើកផ្តល់ប្រាក់ជូនគ្រួសារក្រីក្រ សរុប ៤៧,៨៦១ គ្រួសារ ស្មើនឹងទឹកប្រាក់ ១៤៤,៣៣១,៨៧២,០០០ រៀល ។

-ការអនុវត្តកម្មវិធីជំនួយសង្គមជាសាច់ប្រាក់សម្រាប់គ្រួសារដែលមានអ្នកឆ្លង និងគ្រួសារ ដែលមានអ្នកស្លាប់ ដោយជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ សរុបចំនួន ៧៦០ គ្រួសារ ស្មើនឹងទឹកប្រាក់ ១៣២,៤៨៤,៩០០រៀល ក្នុងនោះ គ្រួសារដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ ចំនួន ៦៤០គ្រួសារ ស្មើនឹងទឹកប្រាក់ ២៦៩,៧៤៤,៦០០រៀល និងគ្រួសារដែលមានអ្នកស្លាប់ ដោយជំងឺកូវីដ-១៩ ចំនួន ១២០គ្រួសារ ស្មើនឹងទឹកប្រាក់ ៨៤,៨២៧,៥០០រៀល។

- **ការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩**

ក្នុងកាលៈទេសៈនៃការរាតត្បាតនៃជម្ងឺកូវីដ-១៩ជាសកល ខេត្តកំពង់ចាម ក៏មិនខុសពី បណ្តារាជធានីខេត្តដទៃឡើយ ខេត្តកំពង់ចាមបានរកឃើញករណីវិជ្ជមានកូវីដ-១៩ លើកទី១ នៅ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២០ បន្ទាប់ពីការមកដល់នៃនាវាទេសចរណ៍ឈ្មោះ Viking cruise journey ដោយបានរកឃើញស្ត្រីជនជាតិអង់គ្លេស វ័យ ៦៥ឆ្នាំម្នាក់ និងបានរកឃើញជាបន្តបន្ទាប់ ករណីវិជ្ជមានកូវីដ-១៩ សរុបចំនួន១៦រូប ក្នុងនោះ ជនជាតិខ្មែរ ០១នាក់ និងជនជាតិម៉ាឡេស៊ី ០៨នាក់ (មកធ្វើពិធីសាសនានៅស្រុកកងមាស) និងជនជាតិអង់គ្លេស ០៥នាក់ អាមេរិក ០២នាក់ និងបានជាសះស្បើយ ត្រឡប់ទៅប្រទេសរៀងៗខ្លួន។ ជាមួយគ្នានេះ ខេត្តក៏បានទទួលរងផលប៉ះ

៣ល់ពីព្រឹត្តិការណ៍ ០៣វិច្ឆិកា ព្រឹត្តិការណ៍ ២៨វិច្ឆិកា ព្រឹត្តិការណ៍សាមុតសាខន នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ និងចុងក្រោយក្នុងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ ត្រូវបានបិទបញ្ចប់កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ កន្លងទៅនេះ បានរកឃើញករណីវិជ្ជមាន ៖ ៨.៤៨១នាក់ (ស្រី ៥.០៨៨នាក់) ក្នុងនោះ ករណីជាសះស្បើយ៖ ៨.១៤៩នាក់ (ស្រី៤.៨៨៥នាក់) ករណីស្លាប់៖ ចំនួន ៣៣១នាក់ (ស្រី២០២នាក់) ស្លាប់ដោយកូវីដ៖ ចំនួន ២១៥នាក់ ស្រី ១៣២នាក់ និងស្លាប់ដោយបញ្ហាផ្សេងៗ៖ ចំនួន ១១៦នាក់ ស្រី៧០នាក់។ បច្ចុប្បន្នកំពុងសម្រាកព្យាបាលមានចំនួន០១នាក់ (ស្រី ០១នាក់)។

អនុវត្តតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋបាលខេត្ត បានរៀបចំចាត់តាំងការអនុវត្តវិធានការនានារបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសុខាភិបាលរួមនឹងវិធានការរដ្ឋបាលនានាដែលរដ្ឋបាលខេត្ត បានដាក់ចេញសំដៅចូលរួមទប់ស្កាត់ការឆ្លងរីករាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍។ ដោយអនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោ** រដ្ឋបាលខេត្ត បានចាត់ចែងរៀបចំប្រែក្លាយសណ្ឋាគារមេគង្គ ទៅជាមន្ទីរពេទ្យសម្រាប់ព្យាបាលជំងឺកូវីដ-១៩ និងត្រូវបានប្រសិទ្ធិនាមជាមន្ទីរពេទ្យមេគង្គកំពង់ចាម និងមានគ្រែចំនួន ២៧០គ្រែ ក្នុងនោះគ្រែICU មាន ៩០គ្រែ។ ជាមួយគ្នានេះ រដ្ឋបាលខេត្ត បានរៀបចំឃ្លាំងពាណិជ្ជកម្ម នៅស្រុកកំពង់សៀម ប្រើប្រាស់បានមួយ រយៈពេល មានគ្រែ ចំនួន៥៩៨គ្រែ គ្រែICU ចំនួន ២០គ្រែ ។

ក្នុងបរិបទថ្មីនៃការរៀនរស់នៅជាមួយជំងឺកូវីដ-១៩ បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវ «**យុទ្ធនាការជាតិចាក់វ៉ាក់សាំង**» សំដៅបង្កើតឱ្យមានភាពស៊ាំក្នុងសហគមន៍ទប់ទល់នឹងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ ប្រជាពលរដ្ឋខេត្តកំពង់ចាម បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី១ ចំនួន ៨៣៩.២៦៨នាក់ ស្មើនឹង៨៩,៧៨%នៃផែនការ៩៣៥.៦៧៤នាក់ និងប្រជាពលរដ្ឋអាយុចាប់ពី១៨ឆ្នាំឡើង បានចាក់ដូសទី៣ ចំនួន ២២៥.៩៦៣នាក់ ស្មើនឹង៣២,២០%នៃផែនការ ៧០១.៧៣៨នាក់ ។ ចាប់តាំងពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២ រដ្ឋបាលខេត្ត បានរៀបចំក្រុមគ្រូពេទ្យចល័ត ចុះយុទ្ធនាការចាក់វ៉ាក់សាំងដូសទី៣ ជូនដល់ប្រជាពលរដ្ឋអាយុចាប់ពី១៨ឆ្នាំឡើង នៅតាមភូមិ និងយុវវ័យអាយុចាប់ពី១២ឆ្នាំ ដល់ក្រោម១៨ឆ្នាំ នៅតាមសាលារៀនផងដែរ។

- **ការអនុវត្តគម្រោងអភិវឌ្ឍន៍ក្នុងខេត្ត**

-គម្រោងខេត្តឆ្នាំ២០២១ មានចំនួន ១៧គម្រោង ក្នុងនោះ៖

**១**)ផ្លូវប្រភេទAC មាន ០២ខ្សែ ប្រវែង ៨៤៤ម៉ែត្រ, **២**)ផ្លូវបេតុងអាមេ មានចំនួន០៤ខ្សែ ប្រវែង ៧.០២៥ម៉ែត្រ, **៣**)ផ្លូវប្រភេទDBST មានចំនួន ០៦ខ្សែ ប្រវែង ១២.៩១១ម៉ែត្រ, **៤**)ផ្លូវក្រាលគ្រួសក្រហម មានចំនួន ០៣ខ្សែ ប្រវែង ១០.១៥៧ម៉ែត្រ, **៥**)សាងសង់ស្ពានបេតុងមានចំនួន ០២កន្លែង (ជំហានបញ្ចប់) ប្រវែង ២២០.៥ម៉ែត្រ, **៦**)សាងសង់លូ មានចំនួន ០២កន្លែង ប្រវែង ៣០១ម៉ែត្រ, **៧**)ជួសជុលស្តារប្រឡាយ និងអាងស្តុកទឹក មានចំនួន ០២កន្លែង ប្រវែង ២.៣០០

ម៉ែត្រ, **៨)**សាងសង់ច្រាំងទន្លេ មានចំនួន ០១កន្លែង ប្រវែង៦០ម៉ែត្រ, **៩)**ជួសជុលអគាររដ្ឋបាល មានចំនួន ០១គម្រោង (ជំហានទី៥), **១០)**ជួសជុលសួនច្បារ, តម្លើងរូបសំណាកដំរី, រៀបបង្កាន់ដៃ, ចាក់សាប បេតុង តាមបណ្តោយទន្លេមេគង្គ និងជួសជុលកែលម្អអាងបាញ់ទឹកចំនួន ៤កន្លែង ក្នុងក្រុងកំពង់ចាម។

- គម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០២១ មានចំនួន ៣៤គម្រោង ចែកជា៖ **១)**ផ្លូវបេតុងអាមេ ២៦ខ្សែ ប្រវែង៧.៤៥០ម៉ែត្រ ,**២)**ជួសជុលផ្លូវដីសរ ០១ខ្សែ ប្រវែង ៤៨០ម៉ែត្រ, **៣)**សាងសង់ផ្លូវក្រាលគ្រួសក្រហម០១ខ្សែ ប្រវែង ២.៥៣០ម៉ែត្រ និង**៤)**ស្តារប្រឡាយ ០២ខ្សែ ប្រវែង២.៩០៥ម៉ែត្រ ។

- គម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ ២០២១ មានចំនួន ១៣៩ គម្រោងចែកជា៖**១)**ផ្លូវបេតុងអាមេចំនួន ១១០គម្រោង ប្រវែង៦១.០៧៧ម៉ែត្រ ,**២)**ជួសជុលផ្លូវក្រាលកំទេចថ្ម ចំនួន ០៤គម្រោង ប្រវែង១៨.២៦៥ម៉ែត្រ ,**៣)**ជួសជុលផ្លូវក្រាលគ្រួសក្រហមចំនួន ១៤គម្រោង ប្រវែង ៦២.៥៣៥ម៉ែត្រ ,**៤)**ជួសជុលផ្លូវដី ចំនួន០៥គម្រោង ប្រវែង២១.៥៨៧ម៉ែត្រ ,**៥)**ស្តារប្រឡាយ ចំនួន ០៤គម្រោង ប្រវែង៤.៥០០ម៉ែត្រ ,**៦)**សាងសង់លូមូលដោះទឹក០២កន្លែង ប្រវែង៨៧៨ ម៉ែត្រ ។

- ក្រៅពីគម្រោងរបស់ខេត្ត គម្រោងមូលនិធិក្រុង ស្រុក និងគម្រោងមូលធិធិឃុំ សង្កាត់ ខេត្តកំពង់ចាមនៅឆ្នាំ២០២១នេះ ក៏ទទួលបាននូវសមិទ្ធិផលជាចំណងដៃពីរាជរដ្ឋាភិបាលកម្ពុជា មាន ផ្លូវ ស្ពាន និងប្រព័ន្ធស្រោចស្រព ដូចខាងក្រោម ៖

**+<u>ស្រុកកោះសូទិន បានទទួលផ្លូវចំនួន ០២ខ្សែ</u>** ៖

- ខ្សែទី១ ផ្លូវស្ពានដើមស្ដៅ ទៅ មហាខ្ញូង (KC1) មានប្រវែង ១៦,០៥០ គីឡូម៉ែត្រ កម្រាលបេតុង ទទឹងខ្នងលើ ៦ ម៉ែត្រ និង ចិញ្ចើមផ្លូវគ្រួសក្រហមសងខាង ០,៥ម៉ែត្រ។

- ខ្សែទី២ ផ្លូវពាមប្រធ្នោះ ទៅព្រែកចង្ក្រាន (KC3) មានប្រវែង ១៤,២០៨ គីឡូម៉ែត្រ កម្រាលបេតុងទទឹងខ្នងលើ ៦ ម៉ែត្រ និង ចិញ្ចើមផ្លូវគ្រួសក្រហមសងខាង ០,៥ ម៉ែត្រ ។

សរុបតម្លៃសាងសង់ផ្លូវទាំងពីរខ្សែមានតម្លៃ ១០,១៨ លានដុល្លារ

**+ <u>ស្រុកកងមាស</u> ៖** ទទួលបានផ្លូវ ០១ខ្សែ ពីផ្លូវ បឹងត្រាវ ទៅ អន្លង់គគីរ(KC2) មានប្រវែង ២៧,៣៥១ គីឡូម៉ែត្រ ជាប្រភេទកម្រាលផ្លូវកៅស៊ូពីរ ជាន់(DBST) ទទឹងខ្នងលើ ៥ម៉ែត្រ និង ចិញ្ចើមផ្លូវគ្រួសក្រហមសងខាង ០,៥ ម៉ែត្រ សរុបទទឹងផ្លូវ ៦ម៉ែត្រ តម្លៃសាងសង់ចំនួន ៣,៥២លានដុល្លារ ។

**+<u>ស្រុកស្រីសន្ធរ</u>** ៖ ទទួលបានប្រឡាយមេ ចំនួន ១២ ខ្សែ និងប្រឡាយរង ៤៦ ខ្សែ មានប្រវែងសរុប ១០៥,៣៧ គីឡូម៉ែត្រ ក្នុងនោះប្រឡាយបេតុង មានប្រវែង ២៧,១៩ គីឡូម៉ែត្រ និងប្រឡាយដី ៧៨,១៧ គីឡូម៉ែត្រ

-សំណង់សិប្បការតូចធំ ចំនួន ១៩៥កន្លែង

-ស្ថានីយបូមទឹកទំនើប ពីទន្លេមេគង្គ មកប្រឡាយមេ ដើរដោយចរន្តអគ្គីសនី បំពាក់ម៉ូទ័រ ០៧គ្រឿង ចំនួន ០១កន្លែង អាចស្រោចស្រពលើផ្ទៃដីរដូវវស្សា ប្រមាណ ៨.០០០ហ.ត និងរដូវប្រាំង ប្រមាណ ៨.០០០ហ.ត។

+<u>ស្រុកស្ទឹងត្រង់</u>៖ កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ សម្ដេចអគ្គមហាសេនាបតិតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **វ៉ាង វិនជៀន** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធស្ពានមិត្តភាពកម្ពុជា ចិន ស្ទឹងត្រង់-ក្រូចឆ្មារ ត្រូវបាន**សម្ដេចនាយករដ្ឋមន្ត្រី** បានប្រសិទ្ធនាម ស្ពាននេះថាជាស្ពានភ្ជាប់និស្ស័យ។ ស្ពានមិត្តភាពកម្ពុជា ចិន ស្ទឹងត្រង់-ក្រូចឆ្មារនេះ មានប្រវែង ១.១៣១ម៉ែត្រ និងបានធ្វើពិធីប្រកាសបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ៧១C មានប្រវែង ១១៤,៦២គ.ម ខេត្តកំពង់ចាម មានប្រវែង ៣២គ.ម ។

មកដល់ពេលនេះ ប្រព័ន្ធទឹកស្អាតទូទាំងខេត្តកំពង់ចាម បានតបណ្ដាញទឹកស្អាត ចូលក្នុងឃុំ សង្កាត់ ចំនួន ១០៧១០៩/ឃុំ សង្កាត់ ស្មើនឹង ៩៨៨៧០ និងគ្របដណ្ដប់ភូមិចំនួន ១៦%, ភូមិ/៩១៦ភូមិ ស្មើនឹង ៩៤,៣២% និងភូមិបានភ្ជាប់បណ្ដាញអគ្គិសនីប្រើប្រាស់ ចំនួន ៩១៤ភូមិ ស្មើនឹង ៩៩,៧៨% ដែលមានប្រជាពលរដ្ឋប្រើប្រាស់ចំនួន ២០១.៣៣៧ខ្នងផ្ទះ

**ក្រៅពីអនុវត្តនូវតួនាទី ភារកិច្ច ដូចបានជម្រាបជូនខាងលើ ក្រុមប្រឹក្សាខេត្តកំពង់ចាម បានចូលរួមជាមួយគណៈអភិបាលខេត្ត និងក្រុមប្រឹក្សាផ្សេងៗទៀត ចុះធ្វើការអប់រំផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងចុះសួរសុខទុក្ខចែកអំណោយជូនប្រជាពលរដ្ឋ ជួបគ្រោះមហន្តរាយផ្សេងៗ ក៏ដូចជាជនក្រីក្រគ្មានទីពឹង។**

- **ក្រុមការងាររបស់រាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម**

ក្នុងឆ្នាំ២០២១ ក្រុមការងាររបស់រាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម ដែលដឹកនាំដោយឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម រួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី ជាក្រុមការងាររបស់រាជរដ្ឋាភិបាលចុះជួយមូលដ្ឋានគ្រប់លំដាប់ថ្នាក់ បានយកចិត្តទុកដាក់បំពេញការងារយ៉ាងសកម្មនៅមូលដ្ឋាន ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋតាមរយៈការធ្វើចុះជួបផ្ទាល់តាមខ្នងផ្ទះ ផ្ដល់ជាជំនួយស្បៀងអាហារជូនដល់ប្រជាពលរដ្ឋដែលត្រូវអនុវត្តវិធានការសុខាភិបាលធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ នៅតាមផ្ទះ។

ព្រមជាមួយនេះ ក្រុមការងារគ្រប់ថ្នាក់ គ្រប់ផ្នែក បានលះបង់ កម្លាំងកាយ ប្រាជ្ញាស្មារតី សម្ភារ ថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ ជួយកសាងសមិទ្ធិផលនានានៅមូលដ្ឋាន ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ ជួយដោះស្រាយ ផ្ដល់ជាសម្ភារ ថវិកា ឧបត្ថម្ភប្រជាពលរដ្ឋក្រីក្រ គ្មានទីពឹង ចាស់ជរា ក្មេងកំព្រា និងប្រជាពលរដ្ឋរងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ ដែលកើតមាននៅមូលដ្ឋាន ប្រកបដោយការទទួលខុសត្រូវ និងលះបង់ខ្ពស់។

ឆ្លៀតក្នុងឱកាសដ៏កម្រនេះ ជូសមុខឲ្យក្រុមប្រឹក្សា គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋនៅទូទាំងខេត្ត ខ្ញុំសូមថ្លែងនូវការអរគុណ ជាពន្លឹកចំពោះកាយវិការដ៏សប្បុរសរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាក្រុមការងាររបស់រាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម ជាពិសេសចំពោះឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយខេត្ត ដែលជានិច្ចកាលជួយឧបត្ថម្ភ និងគាំទ្រទាំងស្មារតី និងសម្ភារ ថវិកា ដល់ខេត្តកំពង់ចាម រយៈពេលកន្លងមក។

III.**ទិសដៅការងារបន្ត ៖**

1. បន្តចុះធ្វើការពិគ្រោះយោបល់ជាសាធារណៈ ជាមួយប្រជាពលរដ្ឋសំដៅឈ្វេងយល់ពីការលំបាក សំណូមពរ និងតម្រូវការនានា នៅមូលដ្ឋាន ដើម្បីរៀបចំផែនការឆ្លើយតប។

2. បន្តចុះធ្វើវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅតាមក្រុង ស្រុក ក្នុងអំឡុងត្រីមាសទី៤ នៃឆ្នាំនីមួយៗ ទៅតាមប្រតិទិនការងារដែលបានអនុម័ត។

3. បន្តកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត ឲ្យបានទៀងទាត់ស្របតាមបទបញ្ជាផ្ទៃក្នុង និងប្រតិទិន នៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាខេត្ត បើមានការចាំបាច់បន្ទាន់អាចប្រជុំវិសាមញ្ញ ។

4. បន្តចាត់វិធានការអប់រំផ្សព្វផ្សាយបទបញ្ជារបស់រាជរដ្ឋាភិបាល និងសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ជូនដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋ ក្នុងការទប់ស្កាត់ជំងឺឆ្លងនានា ពិសេសជំងឺកូវីដ-១៩ ឲ្យមានប្រសិទ្ធភាពខ្ពស់។

5. បន្តគាំទ្រយន្តការការិយាល័យប្រជាពលរដ្ឋ អំពីការទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ ដែលពាក់ព័ន្ធការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាល ។

6. ពង្រឹងទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត និងកៀងគរធនធាននានា ដើម្បីអភិវឌ្ឍន៍មូលដ្ឋាន។

7. ជំរុញ និងគាំទ្រយន្តការច្រកចេញចូលតែមួយ ដើម្បីបង្កិតសេវាសាធារណៈឲ្យនៅកៀកជាមួយប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

8. បន្តរៀបចំការតាមដានត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំនូវផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងគម្រោងផែនការចំណូល ចំណាយ ប្រចាំឆ្នាំ និងសេចក្តីសម្រេចនានា របស់ក្រុមប្រឹក្សាខេត្ត ។

9. បន្តជំរុញ និងគាំទ្រសកម្មភាពរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស សំដៅពង្រឹងសមត្ថភាពដល់មន្ត្រីក្នុងរចនាសម្ព័ន្ធសាលាខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ។

10. បន្តគាំទ្រ និងជំរុញការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពទាំង ០៧ចំណុច សំដៅធានាសុខសន្តិភាព និងសុខដុមរមនានៅមូលដ្ឋាន។

ជាទីបញ្ចប់ ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គសន្និសីទទាំងមូល និងបងប្អូនប្រជាពលរដ្ឋដែលកំពុងតាមដានការផ្សាយបន្តផ្ទាល់ ជាពិសេស ឯកឧត្តម រដ្ឋមន្ត្រីប្រតិភូអម

នាយករដ្ឋមន្រ្តី និងជាប្រធានអង្គភាព អ្នកនាំពាក្យរាជរដ្ឋាភិបាល ព្រមទាំងសហការី ដែលបានផ្តួចផ្តើម រៀបចំអង្គសន្និសីទសារព័ត៌មាននាពេលនេះ និងសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ព្រមទាំងបងប្អូនប្រជាពលរដ្ឋទូទាំងប្រទេស ជាពិសេសប្រជាពលរដ្ឋនៅខេត្តកំពង់ចាម សូមមានសុខភាពល្អ អាយុយឺនយូរ សមប្រកបតែនឹងពុទ្ធពរទាំងឡាយបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបី ឃ្លៀងឃ្លាតឡើយ ។

***សូមអរព្រះគុណ និងសូមអរគុណ!***